# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារទីផ្សារអន្តរធនាគារ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទីទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាស អោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រិត្យលេខ ជស / រកត / ០៣៩៨ / ៨៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការតែតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញអនុស្សារណៈចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០១ រវាងរាជរដ្ឋាភិបាលកម្ពុជានិងក្រុមបេសកកម្ម ស្វែងរកការពិតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងគោលបំណងផ្តល់កម្មវិធីឥណទានអភិវឌ្ឍផ្នែកហិរញ្ញវត្ថុ
- បានឃើញអនុស្សារណៈចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ រវាងរាជរដ្ឋាភិបាលកម្ពុជានិងក្រុមបេសកកម្ម វាយតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងគោលបំណងផ្តល់កម្មវិធីឥណទានអភិវឌ្ឍផ្នែកហិរញ្ញវត្ថុ
- បានឃើញលក្ខន្តិកៈនៃសមាគមធនាគារិកនៅកម្ពុជា

## ស ម្រេ ច

**ប្រការ ១.-**

បង្កើត "ក្រុមការងារទីផ្សារអន្តរធនាគារ" តទៅនេះហៅថាក្រុមការងារ អោយស្ថិតនៅក្រោម ការដឹកនាំរបស់គណកម្មាធិការដឹកនាំផ្នែកហិរញ្ញវត្ថុ ដែលមានតំណាងនិងមន្ត្រីជំនាញមកពីធនាគារជាតិ

នៃកម្ពុជានិងសមាគមធនាគារិក ក្នុងគោលបំណងជួយដល់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តន៍កំណែទំរង់គោលនយោបាយ សំរាប់ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារដែលអាចដំណើរការបាននិងសេវាកម្មផ្សេងៗទៀត ដែលមានចែងនៅក្នុងកំរងកម្មវិធីឥណទានរបស់វិស័យហិរញ្ញវត្ថុដែលរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០១ ។

**ប្រការ ២.-**

ក្រុមការងារត្រូវត្រៀមរៀបចំការងារចាំបាច់ទាំងអស់ដើម្បីបង្កើតនូវ ÷

- ការសំរបសំរួលទីផ្សារអន្តរធនាគារដែលអាចដំណើរការបាន
- ការសំរបសំរួលសំរាប់ការដោះដូរពត៌មានឥណទានក្នុងចំណោមសមាជិកសមាគមធនាគារិកនិង
- វិទ្យាស្ថានធនាគារមួយ សំរាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់បុគ្គលិកនៃសមាជិកសមាគមធនាគារិក ។

ក្រុមការងារត្រូវមានភារកិច្ចដូចខាងក្រោមនេះ ÷

- កសាងផែនការមួយ សំរាប់បង្កើតការសំរបសំរួលការដោះដូរពត៌មានឥណទានក្នុងចំណោមសមាជិកនៃសមាគមធនាគារិក
- រៀបចំសេចក្តីព្រាងការណែនាំរបស់ធនាគារជាតិនៃកម្ពុជាមួយ សំរាប់និតិវិធីនៃប្រតិបត្តិការក្នុងការសំរបសំរួល ដែលរួមមានការតំរូវអោយមានរបាយការណ៍ពីធនាគារពាណិជ្ជ
- ពង្រីកការសំរបសំរួលទីផ្សារអន្តរធនាគារ
- រៀបចំសេចក្តីព្រាង (ក) ពិធីសារនៃប្រតិបត្តិការ (ខ) ក្រមសីលធមិសំរាប់ភ្នាក់ងារនិងឈ្មួញកណ្តាល គុណវឌ្ឍន៍របស់ភ្នាក់ងារ/ឈ្មួញកណ្តាល និង (គ) បញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជាសំរាប់ទីផ្សារអន្តរធនាគារ
- ជំរុញប្រព័ន្ធពត៌មានឥណទាន និងការសំរបសំរួលទីផ្សារអន្តរធនាគារអោយមានការចូលរួមពីគ្រប់ធនាគារជាសមាជិកនិង
- រៀបចំសេចក្តីព្រាងផែនការមួយសំរាប់បង្កើតវិទ្យាស្ថានធនាគារ សំរាប់បុគ្គលិកនៃសមាជិករបស់សមាគមធនាគារិកដោយមានការបើកវគ្គសិក្សាបណ្តុះបណ្តាល និងផែនការផ្តល់មូលនិធិ ។

**ប្រការ ៣.-**

ក្រុមការងារទីផ្សារអន្តរធនាគារ ត្រូវមានតំណាងមន្ត្រីជំនាញមកពីធនាគារជាតិនៃកម្ពុជា ចំនួនបីរូបនិងសមាគមធនាគារិកចំនួនពីររូបជាសមាជិក ។

**ប្រការ ៤.-**

- ក្រុមការងារត្រូវតែងតាំងលេខាធិការមួយរូប
- លេខាធិការរក្សាទុកកំណត់ហេតុប្រជុំរបស់ក្រុមការងារ និងទទួលខុសត្រូវចំពោះការសំរបសំរួល និងផ្តល់ការគាំទ្រខាងផ្នែកសំភារៈទាក់ទងដល់ប្រតិបត្តិការនៃក្រុមការងារ ។

**ប្រការ ៥.-**

- ប្រធានក្រុមការងារត្រូវរៀបចំរបៀបវារៈប្រជុំ ដោយមានការពិគ្រោះយោបល់ជាមួយ លេខាធិការ ។ ប្រធានក្រុមការងារត្រូវរៀបចំខ្លឹមសារជាឯកសារប្រជុំ នៅពេលប្រធានយល់ថាចាំបាច់ដើម្បីសម្រួលដល់ការពិភាក្សា ។
- សមាជិកមួយឬច្រើនរូប ដែលបានស្នើអោយមានការប្រជុំវិសាមញ្ញរបស់ក្រុមការងារត្រូវរៀបចំរបៀបវារៈនិងខ្លឹមសារជាឯកសារដោយពិគ្រោះយោបល់ជាមួយប្រធាន ។
- ប្រសិនបើចាំបាច់ ប្រធានក្រុមការងារអាចស្នើសុំអោយបង្កើតក្រុមជំនាញតូច១ ដើម្បីរៀបចំខ្លឹមសារជាឯកសារ ។

**ប្រការ ៦.-**

- ដើម្បីសម្រួលដល់ការពិភាក្សារបស់ក្រុមការងារដោយមានការចូលរួមពីមន្ត្រីជំនាញប្រធានក្រុមការងារអាចអញ្ជើញអ្នកឯកទេសជំនាញបរទេសនិងក្នុងស្រុក ដែលមានការទាក់ទងដល់ខ្លឹមសារនៃបញ្ហា ។
- ប្រធានក្រុមការងារត្រូវអញ្ជើញអ្នកឯកទេសជំនាញ ដោយគំនិតផ្តួចផ្តើមផ្ទាល់ឬក្នុងនាមជាប្រធានក្រុមការងារដោយផ្អែកលើអនុសាសន៍របស់សមាជិកផ្សេងទៀតនៃក្រុម ការងារ ។

**ប្រការ ៧.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គធិការដ្ឋាន គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គណកម្មាធិការដឹកនាំផ្នែកហិរញ្ញវត្ថុ គ្រប់សមាជិកក្រុមការងារទីផ្សារអន្តរធនាគារ

គ្រប់នាយកដ្ឋាន អង្គភាព និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០០១

**ទេសាភិបាល**

**កន្លែងទទួល**

- ដូចប្រការ៧ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជ្រាបជាពតិមាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "